# ជំនួយនិងការរៀបចំផែនការលើកទឹកចិត្តការងារ ( WIPA )

## តើ WIPA ជាអ្វី ?

កម្មវិធីជំនួយនិងការរៀបចំផែនការលើកទឹកចិត្តការងារ ( WIPA ) គឺជាសេវាឥតបង់ប្រាក់ ដែលជួយដល់អ្នកទទួលអត្ថប្រយោជន៍ពីរបបសន្តិសុខសង្គមដោយផ្អែកលើពិការភាព ធ្វើការជ្រើសរើសដោយបានដឹងព័ត៌មានអំពីគោលដៅការងាររបស់ពួកគេ។ កម្មវិធីនេះគឺសម្រាប់បុគ្គលទាំងឡាយដែលបច្ចុប្បន្ននេះមានការងារធ្វើ ធ្វើការឲ្យខ្លួនឯង ឬអ្នកដែលកំពុងរកការងារធ្វើ ឬចង់ធ្វើការឲ្យខ្លួនឯង។

អង្គការសិទ្ធិជនពិការរដ្ឋកាលីហ្វញ៉ា ( Disability Rights California ) ក្នុងកិច្ចសហប្រតិបត្តិការជាមួយរដ្ឋបាលរបបសន្តិសុខសង្គម ( Social Security Administration ) ផ្តល់សេវា WIPA ដល់អ្នកទទួលអត្ថប្រយោជន៍ពីរបបសន្តិសុខសង្គមក្នុងខោនធី San Diego, Imperial និង Riverside។



## តើនរណាមានសិទ្ធិទទួលបាន ?

ដើម្បីមានសិទ្ធិទទួលបានសេវា WIPA អ្នកត្រូវតែ៖

- ទទួលអត្ថប្រយោជន៍ពីរបបសន្តិសុខសង្គមដោយផ្អែកលើពិការភាពណាមួយ ( SSDI ឬ SSI ) ឬអត្ថប្រយោជន៍ជាសាច់ប្រាក់ ត្រូវបានផ្អាកនាពេលថ្មីៗនេះដោយសារប្រាក់ឈ្នួល។
- មានអាយុយ៉ាងតិច 14 ឆ្នាំ
- មិនមានសិទ្ធិទទួលបានអត្ថប្រយោជន៍ចូលនិវត្តន៍ពីរបបសន្តិសុខសង្គម
- មានការងារធ្វើ ធ្វើការឱ្យខ្លួនឯង ឬកំពុងរកការងារធ្វើ

# តើ WIPA អាចជួយខ្ញុំយ៉ាងដូចម្តេច?

អ្នកសម្របសម្រួលការលើកទឹកចិត្តការងារសហគមន៍ (CWIC) ដែលមានលិខិតបញ្ជាក់ អាចធ្វើការជាមួយអ្នកដើម្បី៖

- ធ្វើផែនការសម្រាប់ឥទ្ធិពលដែលអាចមានពីការងារនោះចំពោះអត្ថប្រយោជន៍របស់អ្នក
- បង្កើតការលើកទឹកចិត្តការងារ ដើម្បីឱ្យអ្នកអាចទទួលជោគជ័យ
- សម្របសម្រួលជាមួយទីភ្នាក់ងារនានា ដែលជួយអ្នកក្នុងការបង់ថ្លៃសម្រាប់ការបណ្តុះបណ្តាល ឬសេវានានាដើម្បីត្រឡប់ទៅធ្វើការវិញ

Disability Rights California



## សេវាទាំងអស់គឺឥតបង់ប្រាក់

## ទាក់ទងមក WIPA តាមរយៈលេខ

## 888-768-7058

ដើម្បីរកមើលបណ្តាគម្រោង WIPA នៅខោនធីផ្សេងទៀត ឬដើម្បីទទួលព័ត៌មានទូទៅអំពីបណ្តាវិធាននៃការងាររបស់ផ្នែករបបសន្តិសុខសង្គម សូមហៅទូរសព្ទទៅខ្សែទូរសព្ទជំនួយការត្រឡប់ទៅធ្វើការវិញ (Ticket to Work Help Line) តាមរយៈលេខ៖ (866) 968-7842 ឬ www.chooseworkttw.net/findhelp/

*ឯកសារនេះគឺទូទាត់ដោយប្រើប្រាស់ប្រាក់អ្នកបង់ពន្ធ តាមរយៈកិច្ចព្រមព្រៀងសហប្រតិបត្តិការជាមួយផ្នែករបបសន្តិសុខសង្គម។ ទោះបីជាផ្នែករបបសន្តិសុខសង្គមបានពិនិត្យឯកសារនេះឡើងវិញដើម្បីសុក្រឹតភាពក៏ដោយ វាមិនមែនជាការផ្តល់ព័ត៌មានផ្លូវការពីផ្នែករបបសន្តិសុខសង្គមឡើយ។*

*អង្គការសិទ្ធិជនពិការរដ្ឋកាលីហ្វញ៉ា 501(c)(3) ត្រូវបានផ្តល់មូលនិធិដោយប្រភពខុសៗគ្នា សម្រាប់បញ្ជីពេញលេញនៃអ្នកផ្តល់មូលនិធិ សូមចូលទៅកាន់ www.disabilityrightsca.org/Documents/ListofGrantsAndContracts.html។*